**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * * *

នៅរសៀលថ្ងៃទី **១៤** ខែ ***សីហា*** ឆ្នាំ២០១៩ ឯកឧត្តម **ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានអនុញ្ញាតឲ្យឯកឧត្តម HIDEHISA Horinouchi ឯកអគ្គរាជទូតជប៉ុន ចូលជួបសម្តែងការគួរសម និងជម្រាបលា ក្នុងឱកាសដែលឯកឧត្តមបានបញ្ចប់បេសកកម្មការទូត នៅព្រះរាជាណាចក្រកម្ពុជា។

**ឯកឧត្តម ឯកអគ្គរាជទូត** មានប្រសាសន៍ថា ក្នុងរយៈពេលបីឆ្នាំនេះ ទំនាក់ទំនងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងប្រទេសទាំងពីរមានការវិវត្តរីកចម្រើន ហើយឯកឧត្តមកត់សម្គាល់ឃើញថា កម្ពុជាបន្តមានការអភិវឌ្ឍរីកចម្រើន និងស្ថិរភាពរឹងមាំ។ ប្រទេសជប៉ុន តាមរយៈការប្រកាសគាំទ្ររបស់ឯកឧត្តមនាយករដ្ឋមន្ត្រីជប៉ុន Abe Shinzo នៅតែបន្តជួយគាំទ្រកម្ពុជានៅលើដំណើរការប្រជាធិបតេយ្យភាវូបនីយកម្មនៅកម្ពុជា ដែលត្រូវបានឆ្លុះបញ្ចាំងអោយឃើញតាមរយៈការផ្តល់ជំនួយដល់ដំណើរការបោះឆ្នោតនៅកម្ពុជា និងការអញ្ជើញអ្នកនយោបាយវ័យក្មេងកម្ពុជា ទៅសិក្សាស្វែងយល់អំពីដំណើរការលទ្ធិប្រជាធិបតេយ្យ នៅប្រទេសជប៉ុន។ ក្នុងក្របខណ្ឌនៃជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ជប៉ុន ឯកឧត្តមក៏បានខិតខំជម្រុញអនុវត្តនិងសម្រេចបាននូវគម្រោងកម្មវិធីជាច្រើន ក្នុងនោះមានការជួសជុលបញ្ចប់ស្ពានមិត្តភាពកម្ពុជា-ជប៉ុន និងគម្រោងទំនើបកម្មកំពង់ផែក្រុងព្រះសីហនុជាដើម។

**ឯកឧត្តម ឯកអគ្គរាជទូត** ក៏បានអរគុណដល់កម្ពុជាផងដែរ ដែលបានគាំទ្រជប៉ុននៅក្នុងវេទិកាអន្តរជាតិនានា ដូចជាការធ្វើកំណែទម្រង់អង្គការសហប្រជាជាតិ និងយុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិកបើកចំហរនិងសេរី ( Free and Open Indo-Pacific Strategy ) របស់ប្រទេសជប៉ុន។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានអបអរសាទរដល់ឯកឧត្តមឯកអគ្គរាជទូត ដែលបានបញ្ចប់បេសកកម្មការទូតប្រកបដោយជោគជ័យដ៏ធំធេងនៅកម្ពុជា និងបានថ្លែងកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងផ្ទាល់ខ្លួន និងការរួមចំណែករបស់ឯកឧត្តមក្នុងការពង្រឹងនិងលើកកំពស់ចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរឲ្យកាន់តែរឹងមាំថែមទៀត។ ក្នុងអាណត្តិរបស់ឯកឧត្តម មានឯកសារជាច្រើនត្រូវបានចុះហត្ថលេខា និងគម្រោងជាច្រើនត្រូវបានអនុវត្ត ដែលពិតជាបានផ្តល់ផលប្រយោជន៍ដល់ការលើកកំពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ និងបន្តរក្សាកំណើនសេដ្ឋកិច្ចនៅកម្ពុជាក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ។

ឆ្លៀតឱកាសនេះ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់រាជរដ្ឋាភិបាល និងប្រជាជនជប៉ុនដែលបានផ្តល់ជំនួយដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅកម្ពុជា ។ ដោយបានទទួលស្គាល់នូវស្នាដៃនិងសមិទ្ធផលទាំងនេះហើយ ទើបបានជាឯកឧត្តមឯកអគ្គរាជទូតបានទទួលបាននូវមេដាយគ្រឿងឥស្សរិយយសរហូតដល់ទៅបីពីរាជរដ្ឋាភិបាលកម្ពុជា។

ទន្ទឹមនឹងនេះ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក៏បានជម្រាបជូនឯកឧត្តមឯកអគ្គរាជទូតផងដែរថា **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ទ្រង់បានសម្រេចព្រះរាជហឫទ័យនឹងយាងចូលរួមពិធីគ្រងរាជ្យរបស់ព្រះចៅអធិរាជជប៉ុន Naruhito នៃរជ្ជកាលរ៉េវ៉ា នៅខែតុលាខាងមុខនេះ។

ឆ្លៀតក្នុងឱកាសនេះ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក៏ជម្រាបជូនអំពីជំនួបរបស់ឯកឧត្តម ជាមួយឯកឧត្តមរដ្ឋមន្ត្រីការបរទេសជប៉ុន Taro Kono ក្នុងឱកាសនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥២ និងកិច្ចប្រជុំពាក់ព័ន្ធនៅទីក្រុងបាងកកនាពេលថ្មីៗនេះ និងមានការពិភាក្សាគ្នាយ៉ាងល្អលើទិដ្ឋិភាពជាច្រើន ទាំងក្នុងក្របខណ្ឌទ្វេភាគី និងអន្តរជាតិ។ ក្នុងជំនួបនោះផងដែរ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ពីសារៈសំខាន់ក្នុងទំនាក់ទំនងកម្ពុជាជាមួយសហភាពអឺរ៉ុប ដោយកម្ពុជាបន្តសហប្រតិបត្តិការ និងសម្របសម្រួលបេសកកម្មអឺរ៉ុបនៅកម្ពុជាជាបន្តបន្ទាប់ ព្រោះរាជរដ្ឋាភិបាលបានផ្តល់ការយកចិត្តទុកដាក់យ៉ាងខ្ពស់ទៅដល់សុខុមាលភាព ក៏ដូចជាជីវភាពកម្មករ និងបងប្អូនក្រុមគ្រួសារដែលទទួលផលប្រយោជន៍ពីការងាររបស់ពួកគាត់។ អាស្រ័យហេតុដូច្នេះហើយទើបកាលពីថ្ងៃទី ១២ ខែសីហា ឆ្នាំ២០១៩ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ បានប្រគល់របាយ-ការណ៍ទៅគណៈកម្មការអឺរ៉ុប ដោយបានបញ្ជាក់ច្បាស់លាស់អំពីវឌ្ឍនភាពនានា ដែលកម្ពុជាសម្រេចបានក្នុងការពង្រឹងលំហរប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងគោលបំណងរក្សាឲ្យបាននូវប្រព័ន្ធអនុគ្រោះពន្ធ EBA ។

ជំនួបនេះ បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល៕

ថ្ងៃ ព្រហស្បតិ៍ ១៥ កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០១៩